**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមលើកទី១របស់ដើមចោទ

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោក J ចៅក្រមនៃសាលាដំបូងខេត្តរតនគិរី**

**<u>កម្មវត្ថុ</u> ៖** សំណើសុំដាក់**ឯកសារត្រៀមលើកទី១របស់ដើមចោទ**ដើម្បីឆ្លើយតបចំពោះ
ឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី ២** នៃក្រមនីតិវិធីរដ្ឋប្បវេណី
-សំណុំរឿងរដ្ឋប្បវេណីលេខ **........**ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

## គ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងឯកសារចម្លើយ

**គ.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"គ.១.១."** នៃឯកសារចម្លើយ ៖ ដើមចោទមិនទទួលស្គាល់។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានទទួលឆ្លើយតបសារពីចុងចម្លើយថា "សូមឲ្យរង់ចាំ ៣ ខែតទៀត"។ ដើមចោទបានទូរស័ព្ទទៅចុងចម្លើយដើម្បីសួរឲ្យបានលម្អិតអំពីមូលហេតុដែលចុងចម្លើយមិនអាចបង់ប្រាក់បានទាន់តាមកាលបរិច្ឆេទ។ ចុងចម្លើយបានពន្យល់ថា គាត់ត្រូវបានមនុស្សអាក្រក់បោកយកលុយជាដើម។ ដើមចោទមានអារម្មណ៍ទៅលើការគិតថា តើចុងចម្លើយពិតជាអាចបង់ប្រាក់ដែលនៅខ្វះចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកបានដែរ ឬ យ៉ាងណា? ច្រើនជាងការគិតថា តើសម្ដីរបស់ចុងចម្លើយនិយាយនោះពិតដែរ ឬយ៉ាងណា? ពីព្រោះ គេបានព្យាករថា តម្លៃរបស់ "ដីL" នឹងនៅតែបន្តកើនឡើង ហើយក៏អាចរកអ្នកទិញបានភ្លាមៗដែរ ដូច្នេះហើយ បើសិនជាចុងចម្លើយមិនអាចរកលុយដែលនៅខ្វះមកបង់ឲ្យបានពិតប្រាកដទេ ដើមចោទនឹង "រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ហើយចង់លក់ទៅឲ្យអ្នកផ្សេង។ម្យ៉ាងទៀត តាមរយៈការឆ្លើយឆ្លងនៅក្នុងទូរស័ព្ទជាមួយចុងចម្លើយ ដើមចោទមិនបានទទួលស្គាល់ថា មានស្ថានភាពដែលចុងម្លើយពិតជាអាចរៀបចំប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកបានទេ ហេតុនេះហើយ ដើមចោទមិនបានតបតចំពោះការទាមទាររបស់ចុងចម្លើយទេហើយបានដាក់ទូរស័ព្ទចុះ **(ភស្តុតាង$X_5$)**។

ដូច្នេះហើយ ការព្រមព្រៀងផ្លាស់ប្ដូរកាលបរិច្ឆេទទៅជាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៩ គឺពុំបានបង្កើតឡើងទេ។

**គ.២.** នៅក្នុងចំណោមអង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"គ.១.២."** នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ទៅលើអង្គហេតុដែលលើកឡើងថា នៅពេលដែលដើមចោទបានទំនាក់ទំនងអំពីការប្រគល់ "ដី L" ចុងចម្លើយបានផ្ញើសារមកថា "សូមឲ្យរង់ចាំ ៣ ខែ តទៀត។" និង អង្គហេតុដែលលើកឡើងថា ក្រោយមក ដើមចោទបានទូរស័ព្ទទៅចុងចម្លើយភ្លាមៗ ។

អង្គហេតុដែលចុងចម្លើយត្រូវបានគេបោកយកលុយ ៖ ដើមចោទមិនដឹង។

អង្គហេតុលើកឡើងថា ដើមចោទបានធ្វើស្ទីការចំពោះសំណើរបស់ចុងចម្លើយអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យា និង អង្គហេតុដែលលើកឡើងថា ដើមចោទបាននិយាយទៅកាន់ចុងចម្លើយថា "ខ្ញុំដឹងហើយ" ៖ ដើមចោទមិនទទួលស្គាល់។

ដូចដែលបានលើកឡើងនៅក្នុងចំណុច "**ក.១.**" ដើមចោទមិនអាចគិតថាចុងចម្លើយអាចបង់ប្រាក់ដែលនៅខ្វះឲ្យបានពិតប្រាកដទេ ដូច្នេះហើយ ទើបមិនបានឆ្លើយតបទៅនឹងសំណើអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យាទេ។ បើទោះបីជា ដើមចោទ បាននិយាយទៅចុងចម្លើយថា "ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញហើយ" ក៏ដោយ ក៏ការនិយាយនោះមិនលើសពីគោលបំណងក្នុងការលើកទឹកចិត្តចុងចម្លើយឡើយ ដោយសារតែ ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះចុងម្លើយនិយាយពិតប៉ុន្តែត្រូវបានគេឆបោក ហើយស្របពេលនោះ ក៏ដល់ពេលចុងឆ្នាំល្មម ដូច្នេះ ការនិយាយបែបនោះមិនមែនជាការឆ្លើយតបចំពោះការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យាទេ។

**ក.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.៣.**" នៃឯកសារចម្លើយ ៖ ដើមចោទមិនទទួលស្គាល់។

**ក.៤.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.២.១.**" នៃឯកសារចម្លើយ ៖ ដើមចោទ ទទួលស្គាល់។[1]

## ខ. ភស្តុតាង

១. កំណត់ត្រាដែលដើមចោទបានសរសេរអំពីខ្លឹមសារដែលបាននិយាយគ្នាតាមទូរស័ព្ទជាមួយចុងចម្លើយ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ (**ភស្តុតាង**$X_5$)

២. ការសាកសួរសាមីដើមចោទ

[1] ចំណុច "គ.២.២." នៃឯកសារចម្លើយ មិនលើសពីការអះអាងអំពីសិទ្ធិរបស់ចុងចម្លើយ (ការអះអាងអំពីការអនុវត្តនូវសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា) ឡើយ ហើយមិនមែនជាការសរសេរនូវអង្គហេតុទេ។ ដូច្នេះហើយ មិនចាំបាច់ធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ទៅលើចំណុច "គ.២.២." នៃឯកសារចម្លើយទេ។

សូម **លោកចៅក្រម**សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

ខេត្តរតនគិរី, ថ្ងៃទី ១  ខែ ឧសភា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"